ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ ១១៨១ អពដ

# សេចក្តីថ្លែងការណ៍

អគ្គនាយកដ្ឋានពន្ធដារសូមធ្វើសេចក្តីថ្លែងការណ៍ឆ្លើយតបនឹងការចុះផ្សាយរបស់សារព័ត៌មានក្នុងស្រុកមួយចំនួន ដែលថ្មីៗនេះ បានចុះផ្សាយនូវលិខិតអនាមិកមួយមានចំណងជើងថា **“មន្ត្រីអគ្គនាយកដ្ឋានពន្ធដារ លាតត្រដាងឈ្មោះមន្ត្រីដែលផ្លាស់ប្តូរតួនាទី និងការងារ ខុសប្រក្រតី”** ។ នេះជាការចុះផ្សាយនូវអត្ថបទដែលគ្មានប្រភពច្បាស់លាស់ គ្មានការទទួលខុសត្រូវ និងចុះផ្សាយដោយមិនបានសាកសួរព័ត៌មានបញ្ជាក់ពីស្ថាប័នដែលមានការទទួលខុសត្រូវ ដែលអាចនិយាយបានថាការចុះផ្សាយបែបនេះមានចរិតលក្ខណៈមួលបង្កាច់ និងធ្វើឱ្យប៉ះពាល់ដល់កិត្តិយសរបស់ស្ថាប័នរដ្ឋ ព្រោះជាការចុះផ្សាយដោយមិនគោរពតាមក្រមវិជ្ជាជីវៈអ្នកសារព័ត៌មាន ព្រមទាំងធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់អ្នកសារព័ត៌មានផ្សេងៗទៀតដែលតែងតែប្រកាន់ខ្ជាប់នូវក្រមសីលធម៌របស់ខ្លួន ។ ត្រឹមតែលិខិតអនាមិកមួយ មិនអាចចេះតែនិយាយបានថាជារបស់មន្ត្រីពន្ធដារទេ លិខិតនេះក៏អាចជារបស់ជនណាម្នាក់ដែលមិនសប្បាយចិត្តចំពោះលទ្ធផលនៃការកែទម្រង់របស់អគ្គនាយកដ្ឋានពន្ធដារ ដែលធ្វើឱ្យប៉ះពាល់ផលប្រយោជន៍ផ្ទាល់ខ្លួនរបស់គាត់ ជាជាងផលប្រយោជន៍របស់ប្រទេសជាតិទាំងមូល ហើយមានចេតនាញុះញង់ បន្ថយបង្អាក់ដំណើរការនៃការកែទម្រង់របស់អគ្គនាយកដ្ឋានពន្ធដារ ។

អគ្គនាយកដ្ឋានពន្ធដារសូមធ្វើការបដិសេធយ៉ាងដាច់អហង្ការ និងទាត់ចោលទាំងស្រុង នូវព័ត៌មានដែលបានលើកឡើងក្នុងអត្ថបទចំណងជើងខាងលើ និងសូមធ្វើការបំភ្លឺជូនសាធារណជនយ៉ាងដូច្នេះថា ÷ អគ្គនាយកដ្ឋានពន្ធដារបានចាប់យករបត់នៃការកែទម្រង់ដែលមិនអាចអត់បាន ហើយជាចាំបាច់ ត្រូវតែធ្វើការកែលំអរគោលនយោបាយសារពើពន្ធ និងរដ្ឋបាលសារពើពន្ធឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ។ ក្នុងន័យនេះ អគ្គនាយកដ្ឋានពន្ធដារបានធ្វើការតែងតាំង និងផ្ទេរតំណែងមន្ត្រីពន្ធដារមួយចំនួន ដើម្បីប្រើប្រាស់ធនធានមនុស្សឱ្យចំទិសដៅ និងស័ក្តិសមទៅនឹងជំនាញរបស់ពួកគាត់ ហើយដែលការតែងតាំងនិងផ្ទេរតំណែងនេះទៀតសោត គឺត្រូវធ្វើឡើងនៅទូទាំងប្រទេស ជាដំណាក់កាលៗ និងត្រូវស្ថិតក្រោមគោលការណ៍កំណែទម្រង់របស់អគ្គនាយកដ្ឋានពន្ធដារ ព្រមទាំងមានការឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយផ្អែកតាមការវាយតម្លៃ និងពិនិត្យលើសមត្ថភាពការងាររបស់សាមីមន្ត្រីនីមួយៗយ៉ាងច្បាស់លាស់ ។ ហេតុអ្វីបានជាការតែងតាំង និងផ្ទេរតំណែងរបស់មន្ត្រីពន្ធដារ សុទ្ធតែមានភាពមិនប្រក្រតី និងមិនមែនក្នុងគោលបំណងពង្រឹងប្រសិទ្ធភាពការងាររបស់ស្ថាប័នទៅវិញ?

លិខិតអនាមិកនេះមានលក្ខណៈភូតកុហក បំភ្លៃ និងបំផ្លើសការពិតដើម្បីបំភាន់មតិសាធារណជន ។ ជាក់ស្តែងដូចជាចំណុចដែលលើកឡើងពីការតែងតាំងទីប្រឹក្សា ជាដើម ។ ជាការពិត អគ្គនាយកដ្ឋានពន្ធដារមិនដែលបានចេញលិខិតបង្គាប់ការ ឬតែងតាំងបុគ្គលណាមួយជាទីប្រឹក្សានោះទេ ។ នេះគឺជាចរិតច្រណែន និន្ទា ឈ្នានីស មួលបង្កាច់ ដែលអាចបណ្តាលមកពីប្រភពមន្ត្រីមួយចំនួនតូចដែលអសកម្ម អសមត្ថភាពការងារ និងបាត់បង់ផលប្រយោជន៍ នៅខណៈពេលដែលអគ្គនាយកដ្ឋានពន្ធដារធ្វើការកែទម្រង់ ដោយមានការអបអរសាទរនិងគាំទ្រយ៉ាងពេញទំហឹងពីមន្ត្រីពន្ធដារភាគច្រើន ដូចដែលមន្ត្រីទាំងនោះបានប្តេជ្ញាចិត្តក្នុងកិច្ចប្រជុំកាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៣ នៅសាលាជាតិពន្ធដារ ។ ករណីនេះក៏អាចជាការមួលបង្កាច់របស់ជនណាម្នាក់ដែលធ្លាប់តែគេចបន្លំពន្ធ ឬប្រកាសបង់ពន្ធមិនត្រឹមត្រូវ ហើយនៅពេលដែល

អគ្គនាយកដ្ឋានពន្ធដារកំណត់ពន្ធឡើងវិញតាមវិជ្ជាជីវៈ និងគោរពតាមគោលការណ៍ច្បាប់ សំដៅធានាបាននូវតម្លាភាព និងសមភាព ដែលជាហេតុធ្វើឲ្យគាត់មិនសប្បាយចិត្ត ហើយឆ្លៀតឱកាសនេះធ្វើការវាយប្រហារ មួលបង្កាច់ បន្ទុចបង្អាក់ សំដៅធ្វើយ៉ាងណាឲ្យប៉ះពាល់ដល់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ស្ថាប័នដែលកំពុងតែធ្វើដំណើរដោយរលូននៅលើផ្លូវនៃការកែទម្រង់ស៊ីជម្រៅ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥នៃរដ្ឋសភា ដែលបាននិងកំពុងតែបន្តជំរុញការអនុវត្តឲ្យកាន់តែស៊ីជម្រៅថែមទៀត នូវកំណែទម្រង់សំខាន់ៗជាអាទិ៍ ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ដែលជាស្នូលនៃអភិបាលកិច្ចល្អ និងជាគន្លឹះក្នុងការបង្កើនប្រសិទ្ធភាពសេវាសាធារណៈជូនប្រជាពលរដ្ឋ ។

អគ្គនាយកដ្ឋានពន្ធដារសូមស្វាគមន៍រាល់ការចុះផ្សាយរបស់សារព័ត៌មានទាំងឡាយណាដែលមានលក្ខណៈរិះគន់ក្នុងន័យស្ថាបនា និងសូមបដិសេធយ៉ាងដាច់អហង្ការចំពោះសារព័ត៌មានដែលបំផ្លើសការពិត និងសូមអំពាវនាវ ព្រមទាំងស្វាគមន៍គ្រប់ពេលវេលាចំពោះកិច្ចសហការ ថែមទាំងផ្តល់រង្វាន់លើកទឹកចិត្តដល់ម្ចាស់លិខិតអនាមិកទាំងឡាយដែលពិតជាមានបំណងរិះគន់ក្នុងន័យស្ថាបនា ដែលចេញមុខមកផ្តល់ភស្តុតាងដែលមានមូលដ្ឋានច្បាស់លាស់ ដើម្បីអគ្គនាយកដ្ឋានពន្ធដារចាត់វិធានការខាងផ្លូវច្បាប់ ក្នុងការទប់ស្កាត់ លុបបំបាត់រាល់បាតុភាពមិនប្រក្រតីដែលបានកើតមានឡើង ។

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៤

**អគ្គនាយកដ្ឋានពន្ធដារ**



មន្ត្រីពន្ធដារប្តេជ្ញា និងគាំទ្រការកែទម្រង់របស់អគ្គនាយកដ្ឋានពន្ធដារ